នៅក្នុងបុរាណនិទានចិន តែងតែមានការរម្លឹកឡើង អំពីភាពកាចសាហាវយង់ឃ្នង ដណ្តើមអំណាចគ្នានៅក្នុងរាជវាំង។ ដំណាក់ខាងក្រោយគឺជាសមរភូមិស្នេហ៍ពិសពុល។ មនុស្សគ្រប់គ្នាត្រូវមានអាវុធបី គឺ ស្អាត វៃឆ្លាតហើយនិងចិត្តដាច់។ ប្រវត្តិសាស្ត្រចិនបានសរសេរខុសៗគ្នា អំពីកំពូលស្ត្រីដ៏ជោគជ័យទាំងអស់នៅពីក្រោយរាជបល្ល័ង្គ ហេតុនេះយើងមានរឿងមួយផ្សេងពេលនេះសម្រាប់អាន គឺ អំពី«ស្នំឯកយ៉ា»។

**ឆ្នាំ១៣៤មុនគ្រឹះសករាជ**...

រដូវនេះ....ធម្មតាមិនទាន់ត្រជាក់ដល់ថ្នាក់នេះនោះទេ ប៉ុន្តែរាជវាំងព្រលប់នេះត្រជាក់ពេកហើយ ។

«យើងមិនគួរណាគយគន់និងបេះផ្កាលេងយូរដល់ពេលនេះ ភ្លេចថាព្រះអង្គនិងយាងមករកក្រយា ឬផ្ទំនៅដំណាក់ក្រហម!»

នេះជាបន្ទូលពីលើគ្រែស្នែងនៃស្នំឯកយ៉ាជាព្រះស្នំត្រូវបានសព្វព្រះទ័យជាងគេក្នុងវាំងនេះ។

«តោះលឿនឡើង» ទាសីអ៊ូ ដែលជាមនុស្សជំនិតជិតព្រះកាយរបស់ស្នំឯកយ៉ាបញ្ជាទៅពួកអាមាត្រដែលសែងគ្រែស្នែង។

តែភ្លាមនោះម្ចាស់គ្រែស្នែងចេញបញ្ជា៖

«ឈប់! ឈប់សិន!»

ស្នំឯកបានបញ្ជាឱ្យគេឈប់គ្រែស្នែង នៅចំពីមុខដំណាក់ដ៏តូចមួយដែលបាំងដោយរបងចាស់និងដើមផ្កាអង្គារ៍សិល្ប៍ស៊ុបទ្រុប។

សម្លឹងពីទីនេះទៅ ឃើញឆ្ងាយគួរសម។ វាជាដំណាក់ចាស់ដែលគេលែងប្រើ ឬអាចថាសម្រាប់ពួកអ្នកបម្រើ ដែលស្នំឯកយ៉ាមិនដែលឆ្លងកាត់។ យប់នេះដោយសារជ្រុលពេល បានជាខំដើរផ្លូវកាត់មកពើបនឹងទិដ្ឋភាពនេះ។

មើលពីនេះទៅ មនុស្សស្រីម្នាក់សក់វែងដល់ភ្លៅកំពុងតែឱបសត្វឆ្មាអង្គុយ។ នាងនោះបែរចំហៀងខ្លួនបានជាមើលមុខមិនឃើញ ប៉ុន្តែកំពុងច្រៀងពីរោះរណ្តំនិងគ្រលួចឡើងៗល្វើយៗតាមខ្យល់។

«ច្រៀងក្នុងវាំង! រំខានគេឯង! ពង្វក់មនុស្សប្រុសជាទោសមួយទៅហើយ ហេតុអីបានមានឱបសត្វចិញ្ចឹមទៀត! ជាសត្វឆ្មាផងព្រះពរ!»

នេះជាពាក្យនិន្ទាស៊កសៀត ដែលជាចំណូលចិត្តរបស់ជំនិតអ៊ូ នៃព្រះស្នំឯកយ៉ា។

សំនៀងស្រួយស្រោករបស់ស្នំឯកយ៉ា ស្រែកឡើងឈប់ឈប់គ្រែស្នែងភ្លាម។

ការជិះគ្រែស្នែងនៅក្នុងវាំងជារឿងកម្រណាស់។ ស្នំឯកនេះ ជាសំណព្វចិត្តរបស់ព្រះរាជានៃរាជវង្ស ប៊ឹង ដែលបានទទួលអំណោយជំនិះពិសេសដោយសារនាងមានជំងឺឈឺជើង។

ស្នំដទៃ តែងតែដើរក្រោមឆ័ត្រ ពីដំណាក់មួយទៅដំណាក់មួយលើកលែងតែឆ្លងកាត់ ព្រៃឫស្សីឬមួយក៏វាលផ្កាធំធេងពេក ត្រូវចុករួយស្រពន់ ក៏អាចស្នើជិះរទេះសេះតែម្ដង។

ស្នំឯកយ៉ាដែលមានអំណាចលើសគេផង តែងតែបង្កើតនូវចរិតលក្ខណៈខុសគេ ទម្រើសនិងបង្អួតអំណាចគ្រប់ទីកន្លែង សូម្បីតែដើរកាត់សួនតូចៗ ក៏នាងមិនដែលឱ្យព្រះបាទប៉ះព្រះធរណីនោះដែរ។

ពេលនេះឱ្យបញ្ឈប់គ្រែស្នែង ច្បាស់ណាស់ពិតជាមានអ្នកកំបុតកមិនខាន។ សន្តិសុខម្នាក់ឈ្មោះ ម៉េន ខ្សឹបខ្សៀវដាក់ភិលៀងក្បែរៗគ្រែស្នែង។

«តាមច្បាប់ ចិញ្ចឹមឆ្មា មានទោសអីដែរនៅក្នុងវាំង?»

ភិលៀងម្នាក់ត្រកូល ហ៊ីន ជាអ្នកស្រុកសានទុង ខ្សឹបឡើងថា៖

«មានរឿងនិទានពីដើមមកថាមានព្រះមហេសីត្រូវបានស្លាប់ដោយអយុត្តិធម៌ក្រោមដៃស្នំឯកម្នាក់ដែលពង្វក់ព្រះរាជា ហើយពួកបរិវារដែលមានសីលមន្តអាគម ធ្លាប់តាមស្រលាញ់ជ្រោមជ្រែងព្រះមហេសីនោះក៏បានស្លាប់តាមសម្បថក្លាយខ្លួនទៅជាឆ្មានឹងអាលបានចូលមកក្នុងរាជវាំងដើម្បីយាយីស្រីស្នំឯក ការសងសឹក»

អាមាត្យនិងភិលៀងនិយាយគ្នាហើយក៏ងៀងភ្នែកមើលគ្នា ជាកិច្ចបញ្ជាក់ថា មនុស្សស្រីកំពុងឱបឆ្មានៅនឹងដៃ មិនអាចរស់បានដល់ថ្ងៃស្អែកឡើយ។

ស្បែកជើងមាសឈានមកដល់ព្រះធរណីក្រោមមេឃត្រជាក់ដ៏សែនត្រជាក់ ដើមឈើនានា កករលុបអស់រូបរាងដើមទៅហើយ សល់តែព្រិលសក្បុសគ្រប់ទិសទី។

មនុស្សស្រីស្គមតូច អង្គុយឱបឆ្មាមួយចំហៀងខ្លួនពិតជាមានចិត្ត ចង់បង្កបញ្ហាជាមួយអ្នកធំដែលយាងឆ្លងកាត់ទីនេះពិតមែន ប៉ុន្តែចៃដន្យម្នាក់នេះ គឺជាស្នំដែលកំពុងល្បីល្បាញថាអាចធ្វើផ្គរភ្លៀងបាន ទោះបីជាកំពុងតែស្ថិតនៅក្នុងរដូវរងាក៏ដោយ។

«ឯង!!! ឯងជាអ្នកណា?»

បម្រើជំនិតឈ្មោះអ្នកនាងអ៊ូ បានសម្លុត ដោយមានអាមាត្យបួននាក់រត់មកតាមរង់ចាំបញ្ជាពីបទចាប់ចង។

ពីក្រោយសសរស្តម្ភចាស់ ស្នំឯកយ៉ាដែលបោះជំហានយ៉ាងញាប់ ត្រូវបានមនុស្សជំនិតគ្រាហ៍៖

«ប្រយ័ត្នរអិលព្រះស្នំ!»

«យើងសួរថាឯងជាអ្នកណា!» ស្នំឯកយ៉ាស្រែកដោយកំហឹង។

ថាហើយទ្រង់ងើបមុខសម្លឹងដំណាក់មួយឆ្ងាយពីគេដែលចាស់និងងងឹត។ ស្ត្រីដែលមានអាវផាយស្តើងគ្មានអាវរងាក្រាស់នៅពីលើស្មា ភ្ញាក់ខ្លួនងាកមករបូតសត្វឆ្មាខ្មៅពីដៃ។ សត្វងាកមកសម្លឹងអ្នកដំណើរហើយគ្រហឹមដាក់។

ស្នំឯកយ៉ាងថយបន្តិច។

«ឯងជានរណាមិនឃើញស្នំឯកយ៉ាទេ ម៉េចក៏មិនប្រញាប់ថ្វាយបង្គំ?»

នៅពេលដែលមានមនុស្សស្រីកម្សត់ខ្វាត់ព្រាត់ងាកមក ស្នំឯកយ៉ាលាន់មាត់ស្រែកទាំងរន្ធត់។ អាមាត្យហូតដាវព្រមៗគ្នា ហើយគ្រប់គ្នាគិតថា ស្នំនឹងសម្លាប់ស្រីនោះចោល ផ្ទុយទៅវិញនាងបែរជាភាន់ភាំងហើយរលើងរលោងទឹកភ្នែក ដក់ដង្ហើមហត់ឡើងៗ ភ័យញ័ររាងកាយ។

ស្រីចម្លែកដែលជាម្ចាស់ឆ្មានោះ បានដើរឡើងមកប្រឈមមុខនឹងស្នំឯកធ្វើឱ្យនាងដកថយ។

សំឡេងនាងលាន់ដូចជាក្អែកបូល៖

«លូហ្វា តើឯងសុខសប្បាយជាទេ?»

«ខ្មោច!ខ្មោច!ខ្មោច!» ស្នំឯងចង្អុលនិងស្រែករកជំនួយ ដៃមួយលើកមកស្ទាបទ្រូងភ័យ ជើងឈានដកថយ ហើយទន់ជើងដួលប៉ុកមកលើកម្រាលទឹកកក។

មនុស្សស្រីម្ចាស់ឆ្មា ដែលកំពុងតែញញឹមត្រជាក់ដូចខ្មោច ភ្នែករបស់នាងស្លុងងងឹត ថ្ពាល់នាងស្គមផត មាត់មានឈាមរឹមៗបណ្តាលឱ្យពួកស្រីស្នំទាំងឡាយក៏តក់ស្លុតរត់ហើយស្រែក។

រាងកាយរបស់មនុស្សស្រីម្ចាស់ឆ្មា រសាត់អណ្តែតស្លេវមកហើយ ពួកគេជឿថា ពួកគេបានជួបខ្មោច។

«ឯងនឹងស្លាប់លូហ្វា ស្លាប់យ៉ាងវេទនា!»

ជំនិតអ៊ូខំតាំងស្មារតីស្រែកថា៖

«យើងយាងស្មឹងកឡើងគ្រែស្នែងវិញ!»

នាងនិយាយសឹងតែមិនចង់ចេញទេ ខណៈដែលងាកមកឃើញស្មឹងកយ៉ាទន់ជង្គង់ទៅលើដី។ មិនទាន់ឈានទៅគ្រាប់ទ្រង់ឡើងផង ពេលនោះភ្លេងរៀបការយ៉ាងស្រងេះស្រងោចមួយ បានលាន់ឡើងធ្វើឱ្យគ្រប់គ្នាចាប់អារម្មណ៍មើលមុខគ្នាយ៉ាងស្លេកស្លាំង។

អ្នកណាទៅដែលហ៊ានមករៀបការក្នុងវាំង?

ពួកគេក្រឡេកទៅឆ្ងាយតាមស្នូរដែលបានឮ។ មើលទៅពីចម្ងាយ ក្នុងរលកផ្សែងស្រអាប់នារាត្រីកាលត្រជាក់ដល់ឆ្អឹង គ្រែស្នែងកូនក្រមុំមួយបានហោះ ដោយមានមនុស្សស្រីស្លៀកសបួននាក់ មិនមានជើង។ ពួកគេអណ្តែតនិងលើកគ្រែស្នែងហោះតាមខ្យល់។

ពួកអាមាត្យរញីរញ៉ៃរកាន់ដាវស្ទុះចូលទៅរកកាប់ស្រ្តីខ្មោច ប៉ុន្តែនាងបាត់ស្រមោលទៅហើយ ចំណែកឯសត្វឆ្មាក៏មិនឃើញមានទៀតដែរ។

ពួកគេសម្លឹងជុំវិញខ្លួន ត្រៀមប្រយុទ្ធ ក៏គ្មានឃើញអ្នកណាទាំងអស់បែរជាឃើញស្មឹងកយ៉ាជាម្ចាស់ផ្កាប់មុខទៅនឹងដី។

**បីខែក្រោយមក**.....

នៅក្រោមអាកាសធាតុកាន់តែត្រជាក់គ្មានពន្លឺព្រះចន្ទ រាជវាំងនេះមានការភ័យព្រួយរៀងរាល់រាត្រី ដោយសារដំណើរបាត់ខ្លួនអ្នកបម្រើនិងអ្នកយាមជាបន្តបន្ទាប់។

មិនមាននរណាហ៊ានបង្ហាញខ្លួននៅពេលយប់នោះឡើយ។ រយៈពេលបីខែចុងក្រោយ មានមនុស្សបាត់ខ្លួនទៅជាបន្តបន្ទាប់ ខ្លះក៏រកឃើញសាកសពនៅក្នុងអណ្តូង ខ្លះទៀតនៅព្រៃឫស្សីសែនឆ្ងាយ ខ្លះទៀតបាត់ខ្លួនតែម្តង។

មានពាក្យចចាមអារ៉ាមថា ស្មឹចំណាស់ម្នាក់ ដែលមានជំងឺវិកលចរិតត្រូវបានឃុំនៅជិតព្រៃខាងក្រោយរាជវាំង បានប្រទះឃើញស្រីអភិជនស្លៀកពាក់សូត្រពណ៌ក្រហម ដើរស្វែងរកចាប់មនុស្សខាំហែកបរិភោគ ដោយម្រាមដៃវែងវែង និងចង្កូមមុតថ្លា។

ទោះបីគាត់មានសតិមិននឹងនរ តែពាក្យចចាមអារ៉ាមអំពីបិសាចអាវសូត្រក្រហមដែលមានក្រចកនិងចង្កូមវែងៗ ថែមទាំងមានសំឡេងដូចជាសត្វឆ្មា បានលាន់រំពងពេញវាំង។

មនុស្សខ្លះអះអាងថា មនុស្សស្រីគ្រងអាវសូត្រក្រហមជាស្នំឯកយ៉ា ដែលមានការយាមកាមដំណាក់តឹងរឹង មិនមានអ្នកណាចេញចូលបាន។

ដំណឹងនេះបានលេចឮរហូតកើតក្ដៅក្រហាយដល់ព្រះរាជា ដែលព្រះអង្គបានចេញមកសមរភូមិឆ្ងាយ។ ទ្រង់បានចាត់តាំងមន្ត្រីផ្នែកព្រហ្មទណ្ឌឱ្យធ្វើការស៊ើបអង្កេតក្នុងវាំងជំនួសទ្រង់សិន ទម្រាំរៀបរយនៅបន្ទាយ ហើយទ្រង់នឹងវិលទៅរាជវាំងវិញរកការពិតលើករណីនេះ។

ដូច្នេះយប់នេះ ក្រុមមន្ត្រីព្រហ្មទណ្ឌបានចាប់នារីចំណាប់ចំនួនម្នាក់ ដែលយកមកពីឆ្ងាយគ្មានអ្នកណាស្គាល់ ក្លែងបន្លំធ្វើជាពាក្យភិលៀងទាបតូច ក្នុងឈុតសម្លៀកបំពាក់ពណ៌ប្រផេះ និងកាន់ថាសនំសែនព្រះខែ ក្លែងបន្លំឈ្មោះថា ភិលាងម៉ា។

ភិលៀងនេះបានធ្វើដំណើរយ៉ាងញាប់ជើង ពីចំណុចមន្ត្រីព្រហ្មទណ្ឌ ឆ្ពោះកាត់ទីតំណាក់ស្នំឯកយ៉ា។ ដំបូងឡើយ នាងក្លែងដំណើរជាញាប់ញ័រភ័យខ្លាចឆ្ពោះទៅកាន់ដំណាក់ខាងត្បូង ដែលជាតំបន់ល្បីថាគ្មានអ្នកណាហ៊ានដើរកាត់ ក៏ជាទីកន្លែងដែលប៉ុន្មានខែមុនស្នំឯកថាបានប្រទះឃើញស្រីចម្លែកម្នាក់ គ្មានជើងនិងឱបឆ្នាមួយ។

មិនយូរទេ ភិលៀងនឹងឆ្លងផុតទីនេះ ដល់ក្បែររបងដំណាក់ស្នំឯកយ៉ាមិនខាន ក៏មិនមានការព្រួយបារម្ភអ្វីព្រោះអាងថាមានមន្ត្រីសន្តិសុខតាមឃ្លាំមកពីក្រោយ។

ស្នូរជើងមនុស្ស...សញ្ញាអ្វីមួយមកពីឆ្ងាយត្រសៀកៗតាមខ្យល់ ក៏ភិលៀងម៉ាមិនមានការបារម្ភអ្វីទាំងអស់ព្រោះគិតថា គឺជាក្រុមមន្ត្រីសន្តិសុខដែលការមកការពារនាងនិងស្វែងរកការពិត។

«ភិលៀង នាងទៅណាហើយមានអ្វីក្នុងដៃ?»

គឺជាសំឡេងស្រួយស្រើបដែលធ្វើឱ្យភិលៀងម៉ាឈប់ជើង។ ដោយងាករកប្រភពសំឡេង គ្មានឃើញមនុស្សនោះទេ នាងក៏មិនឆ្លើយតប ហើយប្ដេជ្ញារួសរាន់បន្តដំណើរទៅមុខទៀត។

ទោះបីដឹងថាមានគេតាមការពារប៉ុន្តែម៉ានៅតែមានអារម្មណ៍ញញើតញញើម។

«នំនៅលើដៃឯង ឱ្យមកយើងបានទេ!»

«មិនបានទេ!»

នាងឆ្លើយភ្លាម ក៏ដឹងថាខ្លួនជ្រុលជាល្មើសនឹងបំរាមមួយនៅក្នុងវាំង ដែលចាស់ៗចំណាំបានលើកឡើងតបគ្នាថា ប្រសិនបើយើងដើរហើរកណ្ដាលអធ្រាត្រ ហើយមានគេនិយាយមកតម្រង់ឈ្មោះយើង ទាំងមិនបានឃើញរូបរាងគេ មិនត្រូវឆ្លើយតបនោះទេ។

ដូច្នេះ ម៉ាបានចាប់ផ្ដើមបែកញើស ព្រឺសម្បុរខ្នង ហើយរោមមួយតួខ្លួនបានបះឡើង។

ចាប់ផ្ដើមឈប់ដើរព្រោះជើងទន់ខ្លាំងណាស់។

នៅពេលភិលៀងឈរស្ងៀម កន្ទុយភ្នែករបស់នាងបានឃើញស្រមោលមួយធំនៅលើកម្រាលទឹកកក ដូចជាមនុស្សស្រីដែលមានដំណើរទន់ ប៉ុំងពៀច ឬក៏មិនមានជើង ហោះបន្សាត់នៅក្នុងឈុតសូត្រដ៏ក្រាស់ធំ។

នាងខំស្វែងរកមើលក្បាល បើសិនជាមានក្បាលប្រាកដជាមនុស្សមិនមែនខ្មោចនោះទេ។ ពិតណាស់ ម៉ាអរភើត ព្រោះឃើញស្រមោលផ្នួងសក់ដ៏ធំ ដែលត្រូវបានបួងដាក់ឃ្នាបមាស សក្ដិសមតែជាម្ចាស់ក្សត្រី។

នាងប្រញាប់ថយឱនលំទោនក្បាលរួចលួចមើល។

ឃើញពិតណាស់ ជាស្នំឯកយ៉ាដ៏ល្បីនៅក្នុងវាំងដែលជាសំណព្វព្រះហឫទ័យនៃព្រះរាជា។

«ក្រាបទូលព្រះស្នំ! ខ្ញុំម្ចាស់យកនំនេះត្រលប់ទៅកាន់ដំណាក់ចុងភៅវិញ ជានំសេសសល់ពី មន្ត្រីព្រហ្មទណ្ឌមិនពិសាទៀត!»

«ចុះហេតុអីឯងស្មោះត្រង់ម្ល៉េះ នំឆ្ងាញ់យ៉ាងនេះ ម៉េចក៏ឯងមិនហូបទៅ!»

ដៃដ៏វែងមួយលូកមកពីចម្ងាយ នៅលើវាលទឹកកកមកដល់ថាសរបស់ភិលៀងម៉ាដែលកំពុងតែឈរនៅលើផ្លូវបៀងនៃដំណាក់ខាងត្បូង។

ដៃនាងម៉ាញ័រដៃទទ្រើតកាន់ថាសដូចជាត្រូវឆក់ខ្សែភ្លើង។ ថ្គាមនាងរឹងដូចជាស្រែកមិនបានទោះបីជាដឹងថាមានមន្ត្រីព្រហ្មទណ្ឌនៅជិតៗនេះក៏ដោយ។

«ជួយ! ជួយខ្ញុំ! ផង! ខ្មោច!»

ស្នំឯកដែលមានដៃនិងអាវសូត្រដ៏វែងបួនប្រាំម៉ែត្រចាប់កាន់យកនំ ឯស្រមោលបានរំកិលគៀកឡើងៗ។

ម៉ាធ្លាប់តែចាំគេនិយាយថា ខ្មោចគ្មានស្រមោលនោះទេ។ ធម្មជាតិនាងជានារីលក់ជ្រូក មិនខ្លាចឈាមនិងមានកម្លាំងដូចប្រុស មិនជឿអំពីខ្មោចព្រាយអ្វី ពេលនេះបានឃើញផ្ទាល់ភ្នែកក៏រាកនោមជាប់នៅនឹងកន្លែងឈានទៅណាមិនរួច ទុកឱ្យស្រមោលបិសាចគ្របដណ្តប់មកលើនាង រហូតដល់នាងស្រែកខ្វរយប់តែម្នាក់ឯង។

ចាប់ពីពេលនោះមក គ្មាននរណាបានឃើញភិលៀងម៉ាទៀតនោះទេ។

នៅយប់នោះដែរ មន្ត្រីព្រហ្មទណ្ឌទាំងអស់ដែលតាមពីក្រោយនាងមក ត្រូវបានខ្យល់ត្រជាក់សណ្តំឱ្យដេកលក់អស់។ ក្រោយភ្ញាក់ឡើងដោយមិនដឹងថាមានអ្វីកើតឡើងទាំងអស់។ ចំណែកនុយដែលពួកគេបានដាក់ គឺភិលៀងម៉ា ត្រូវបានគេរកឃើញសាកសពពីរថ្ងៃក្រោយមក ក្នុងព្រៃខ្មោចមួយដែលនៅសេសសល់សាច់ឈាមខ្លះ ចំណែកខ្លះទៀតដូចជាត្រូវហែកដោយចង្កូមសត្វនិងក្រចកដៃ។

រឿងរ៉ាវកាន់តែល្បីរន្ទឺឡើងរហូតដល់ពួកស្រីស្នំផ្សេងៗត្រូវបានគេខ្សឹបថា កុំលូកលាន់ជាមួយស្នំឯកយ៉ាពីព្រោះនាងតាមពិតគឺជាបិសាចដែលមានមានមន្តអាគមជ្រៅជ្រះ អាចល្បួងលួងលោមព្រះរាជាឱ្យព្រះអង្គសព្វព្រះទ័យ ហើយធ្វើឱ្យគ្រប់គ្នា ស្លាប់ឱ្យតែជាមនុស្សស្រី បើហ៊ានចាកចេញពីកន្លែងនៅពេលយប់។

រយៈពេលប៉ុន្មានថ្ងៃនេះព្រះរាជា មិនសប្បាយព្រះទ័យជាខ្លាំង ក៏យាងនិវត្តមករាជវាំង។ ខុសទម្លាប់ដែលងុបងល់រកតែនាងយ៉ាមកនែបនិត្យក្បែរកាយ ព្រះអង្គមិនព្រមទទួលស្នំយ៉ាចូលមករាជសយនាទៀតទេ។

យប់នោះទ្រង់កំពុងតែនៅជាមួយស្នំថ្មីម្នាក់ ឈ្មោះហួយ ស្រាប់តែកណ្តឹងមាសនៅមាត់ទ្វាររោរាំជាសំឡេងឡើងដូចជាសន្ទឹកខ្យល់បោកមកខ្លាំង។

ព្រះអង្គបានតើនឡើងយ៉ាងរឹកវរពីការផ្ទំមួយស្របក់ រួចញីភ្នែកស្រែករកអាមាត្រ ពួកមហាត្លឹក អ្នកបម្រើគ្រប់ថ្នាក់។

ស្ងាត់សូន្យ គ្មានភិលៀង សេនាណាឮ កម្រើក ឬមានវត្តមានចូលមកតាមការប្រកូកសោះ។

«ពួកឯង! ពួកឯង? ហេតុអ្វីមានខ្យល់ខ្លាំងម្ល៉េះ?»

គ្មានអ្នកណាតបតទាំងអស់។

រាជាងាកមកស្រីស្នំដែលនៅក្បែរព្រះកាយ ក៏ដេកលក់ដូចស្លាប់ ខំអង្រួនក៏នាងមិនភ្ញាក់។

ទ្រង់បែកញើសស្អិត។ មិនថានេះជាសុបិនឬអ្វី ជាវេនទ្រង់ត្រូវដឹងការពិតហើយ។

មានស្រមោលមនុស្សឈរនៅខាងក្រៅ ក្រោមព្រិលរពុយ។

«អ្នកណា?»

គ្មានសំឡេងតប មានតែសន្ធឹកខ្យល់ផ្លុំនិងកណ្ដឹងវាំងត្រូវអង្រួន។

«ឮយើងសួរទេ!»

រហូតដល់ឮសំណើចនៅខាងក្រៅក្រឡាបន្ទំ បន្ទាប់មកគឺសំឡេងយំយែករបស់មនុស្សស្រីដែលទ្រង់ចំណាំបាន។

«ស្វាមី ហេតុអ្វីបានជាអ្នកក្បត់ចិត្ត ទៅឱបថ្នមមនុស្សស្រីផ្សេងចោលខ្ញុំម្ចាស់?»

ព្រះអង្គឮហើយកើតព្រឺព្រួច ប៉ុន្តែជាតិជាអង្គស្ដេច មិនអាចមានការបាក់បបខ្លបខ្លាចអំណាចពួកបិសាចអ្វីនោះទេ។ ទោះណាជាច្បាស់ថា សំឡេងរបស់ស្នំឯកយ៉ាដែលព្រះអង្គសែនសព្វព្រះទ័យ ក៏ទ្រង់នៅតែប្រទាញហូតដាវនាគ ដើរតម្រង់មួយៗមករកបង្អួចយ៉ាងអង់អាច។

នៅចន្លោះវាំងននស្បៃសូត្រ ព្រះអង្គបានឃើញស្នំឯកយ៉ាក្នុងឈុតសូត្រក្រហមរៀបការ កំពុងតែឈរយំ ក្រោមដើមផ្កាអង្គាសិល្ប៍ត្រសាយត្រសុំ។ ដៃនាងមានឱបសត្វឆ្មាមួយទៀត។

ឆ្មានេះមែនទេ នាងបញ្ជាឱ្យហែកឆីពេញវាំង?

ស្ដេចចង្អុលមុខនាងបិសាចហើយស្រែកសួរៈ

«ឯងបានធ្វើអ្វីខ្លះ? ឯងក្លាយទៅជាបិសាចហើយមែនដែរទេ? ឆាប់លុតជើងនិងឱនក្បាល ទោះបីនេះក្នុងសុបិន ក៏យើងនឹងសម្លាប់ឯង កាប់ឯងជាកង់ៗ»

«ព្រះអង្គបានសន្យាថានឹងរៀបការជាមួយខ្ញុំម្ចាស់ ប៉ុន្តែបែរជារៀបការជាមួយលូហ្វាទៅវិញ!»

ប្រាំបួនខែមុននេះ ព្រះរាជាប៊ឹងដែលនឿយហត់ក្រោយការបរបាញ់ បានឆ្លងកាត់ភូមិចាស់តូចមួយឈ្មោះ សុនយី។ នៅទីនោះមានគ្រួសារអភិជនមួយដែលល្បីខាងសម្បូរទ្រព្យសម្បត្តិ ចេះជួញព្រៃថ្មីកនិងចេះវិជ្ជាអក្សរសាស្ត្រ គឺអ្នកប្រាជ្ញ យ៉ា ស៊ី។ គាត់មានកូនស្រីតែម្នាក់គត់ឈ្មោះថា យ៉ា តឹង ដែលមានវ័យដប់បួនឆ្នាំ។

អ្នកនាងយ៉ា មានសម្រស់សែនស្រស់បំព្រងនិងល្បីសុសសាយ។

ព្រះអង្គក៏បានចូលទៅសុំសំណាក់នៅ ហើយសុំស្គាល់ជាមួយនឹងកូនស្រីផ្ទះយ៉ា។ បន្ទាប់ពីពេលនោះទ្រង់បានសន្យាថា លុះទ្រង់វិលទៅដល់រាជវាំងកាលណា នឹងចាត់គ្រែស្នែងមកទទួលសែងយកនាងចូលវាំង ដំឡើងឋានៈជាអ្នកស្រីយ៉ាពេញមុខ។

រយៈពេលប្រាំពីរថ្ងៃក្រោយមក រាជាប៊ឹង ក៏បានធ្វើតាមសន្យា លើកតម្កើងនាងរំលងឋានៈក្រឹត្យក្រមរហូតមានឈ្មោះជាស្នំឯកត្រឹមរយៈពេលមួយរាត្រីតែប៉ុណ្ណោះ ធ្វើឱ្យការប្រចណ្ឌច្រណែនកើតឡើងពាសពេញរាជវាំង ប៉ុន្តែមិនមានអ្នកណាអាចធ្វើអ្វីនាងឡើយ។

ស្នំឯកថែមទាំងមានគ្រែស្នែងនិងមានអាមាត្យតាមអាចហែហមមិនខ្វះមុខក្រោយ មានពួកភិលៀង យាយអក បាវបម្រើរាប់មិនអស់។

ព្រះអង្គបានហូតដាវខ្វាច់ស្ទុះមកក្រៅ ក្រោយពីរំឭករឿងអតីតកាលនោះហើយ។

មកដល់ក្រោមរស្មីចន្ទព្រាលពណ៌លឿងស្រពោន ព្រះអង្គប្រុងទោរទន់ចិត្តនឹងទឹកភ្នែករបស់នាង បទចម្រៀងនាងសូត្រខ្សឹកខ្សួលរាត្រីត្រជាក់«សម្បថទឹកតែ ស្នេហាប្រែជាឆ្ងាយ ជាតិនេះនិងជាតិឆ្ងាយ បែរជាទន្ទោលជាកម្ម»។ នាងស្រក់ទឹកភ្នែកយ៉ាងខ្លាំងដូចជាមានរឿងអ្វីមួយលាក់លៀមសែនឈឺចាប់ខ្លោចផ្សា ធ្វើឱ្យទ្រង់សួរនាំឡើង។

«មានអ្វីមិនអស់ចិត្តក៏ប្រាប់យើងមកចុះ យើងនឹងបំពេញបំណងឱ្យក្នុងនាមជាប្ដី!»

ប៉ុន្តែនាងតបវិញថា៖

«សូម្បីជាប្ដី ក៏បានត្រឹមស្រមៃ!»

ស្ដេចនៅស្ងៀមគិតមិនយល់សម្ដីនេះ ប្រុងចូលសួរនាំគ្នា ស្រាប់តែក្រឡេកឃើញក្រចកនាងលូតភ្នែកនាងក្រឡោតឡើងៗ មាត់នាងរីមៗដោយតំណក់លោហិត។

នាងតាមពិតជាបិសាច។

ទ្រង់មិនអាចបណ្ដោយអង្គអាត្មាឱ្យស្លាប់ក្រោមដៃនាងទេ ព្រះរាជាយាហត្ថាកាត់ផ្ដាច់ក្បាលនាងទម្លាក់ទៅក្រោយ ហើយបានក្លាយទៅជាក្បាលឆ្មាមួយយ៉ាងធំគួរឱ្យព្រឺស្ញើប។

ចំណែកសត្វនៅលើដៃនាង បានហក់មក ក៏ត្រូវព្រះអង្គកាត់ចេញជាពីរក្លាយជាផេះរលាយក្នុងខ្យល់។

ព្រះរាជាបានប្រកូកប្រកាសឃើញពួកអាមាត្យមន្ត្រីដឹងខ្លួនពីសណ្ដំ រត់មកដល់ហើយប្រមូលសាកសពស្នំឯកយ៉ា ប៉ុន្តែមេទ័ពម្នាក់ឈ្មោះលូ បានស្រែកឡើងថា «ព្រះអង្គអើយទតចុះ!»

នៅពេលដែលព្រះអង្គគន់គូរមើលទៅ គឺព្រះកេសរបស់ស្នំឯកយ៉ាដែលរបូតធ្លាក់មិនមែនជានាងទៀតនោះទេ ក៏មិនមែនជាក្បាលឆ្មាបែរជាស្ត្រីម្នាក់ផ្សេងទៅវិញ ដែលមានរូបរាងអាក្រក់។

តើមានអ្វីកើតឡើង?

ពួកគេក៏ទទួលបទបញ្ជាឱ្យបោះបង់ចោលសពនេះកណ្ដាលព្រៃ។

រំលងប៉ុន្មានថ្ងៃក្រោយមក ព្រះរាជាបានយាងត្រឡប់ទៅកាន់ភូមិដដែល ដើម្បីស្វែងរកការពិតនៅទីនោះ។ របស់គ្រួសារយ៉ាបានក្លាយទៅជាស្ងប់ស្ងាត់ ព្រោះផ្ទះមានដាក់គោមស កាន់ទុក្ខ។

ឪពុករបស់នាង បានក្លាយជាអាចារ្យ ហើយបានរៀបរាប់ប្រាប់ថា កាលពីប្រាំបួនខែមុន គឺយប់មុនមួយថ្ងៃដែលគ្រែស្នែងព្រះមហាក្សត្របានបញ្ជូនមកដល់ កូនស្រីត្រូវបានសម្លាប់ខ្លួន ចងសំកាំងនៅលើធ្នឹមផ្ទះដោយគ្មានមូលហេតុពិតប្រាកដ។

កាលពីពេលថ្ងៃ នាងសប្បាយចិត្តជាខ្លាំងក្នុងការត្រៀមខ្លួនទៅចួបព្រះមហាក្សត្រដោយបានអប់សាច់និងតុបតែងឈុតសូត្រក្រហមរងាល។

នៅក្នុងយប់ដដែល ស្ត្រីបម្រើម្នាក់ឈ្មោះលូហ្វា ជាកូនស្រីរបស់អ្នកបម្រើជាន់ទាប នៅផ្ទះបាយក៏បានបាត់ខ្លួន។

ព្រះមហាក្សត្រក៏បានចាត់ចែងឱ្យស៊ើបមើលក្នុងបន្ទប់របស់នាងនិងកន្លែងផ្សេងៗទៀតនៅក្នុងផ្ទះត្រកូលយ៉ា ក៏រកឃើញទីកន្លែងសម្ងាត់ដែលអ្នកបំរើស្រីឈ្មោះលីនហ្វានឹងម្ដាយចេះធ្វើមន្តអាគម។ ពួកគេមានកំណើតជាជនជាតិ ប៊ូតានដែលត្រូវបានលក់មកឱ្យគ្រួសារនេះ។

ដោយមានចិត្តច្រណែនម្ចាស់ពួកគេ ម្ដាយនិងកូន បានយកឈាមឆ្មាខ្មៅ និងរូបសំណាកសារតាំងជាសត្វឆ្មាមកបូជាជាគ្រូបាអាចារ្យ។

នៅពេលអាគមសណ្ឋិតពួកគេក៏អាចក្លែងខ្លួនធ្វើជាស្នំយ៉ានិងត្រៀមក្លែងបន្លំចូលទៅក្នុងវាំងជំនួសឱ្យម្ចាស់របស់ខ្លួន។ ចំណែកអ្នកនាងយ៉ាពិតប្រាកដត្រូវធ្វើឃាត និងចងលើធ្នឹម។

ជារៀងរាល់ថ្ងៃ នៅក្នុងរាជវាំង ស៊្នំយ៉ាក្លែងខ្លួនមិនដែលចាកចេញពីដំណាក់ទេនៅពេលថ្ងៃ។ នាងមានជំងឺកែងជើងតាំងពីតូច ដូច្នេះដំណើររបស់នាងមិនល្អដូចអ្នកដទៃ នាងក៏មិនចង់ឱ្យអ្នកណាបានឃើញនាងដើរឡើយ នាងក៏បានទាមទារស្នើសុំឱ្យមានគ្រែស្នែងមួយពីព្រះមហាក្សត្រ។

ពេលដែលគ្រប់យ៉ាងត្រូវបានលាតត្រដាងហើយ វិញ្ញាណរបស់អ្នកនាងយ៉ាក៏ត្រូវបានគេដំឡើងឋានៈទៅជាស្នំឯកយ៉ាពេញលក្ខណៈនិងបានធ្វើការបូជាដើម្បីឱ្យបានទៅកាន់សុគតិភព។

រឿងនេះត្រូវបានចែករំលែក ជាទូទៅនៅក្នុងប្រទេសចិនក្លាយទៅជាជំនឿថា ដរាបណាប្រពន្ធរបស់ស្ដេចត្រូវបានគេសម្លាប់ វិញ្ញាណរបស់នាងនឹងពឹងលើខ្មោចឆ្មា ដើម្បីអាចស្វែងរកយុត្តិធម៌ឱ្យខ្លួនឯង ឬផ្លោះចូលទៅកាន់ព្រះបរមរាជវាំងសម្ញំលបស្រណោះអាលោះអាល័យមើលប្ដីរបស់នាងពីចម្ងាយ។

**ចប់**